Labor

សអ៊ី
MOSALVY

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ៣១៦ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០០១

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់កម្មករនិយោជិតប្រភេទខ្លះខុសពីម៉ោងធ្វើការរួម

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

# សំរេច

ប្រការ១.- ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានមានសិទ្ធិប្រើប្រាស់កម្មករនិយោជិតរបស់ខ្លួន ខុសពីម៉ោងធ្វើការដែលបានកំណត់ជារួម។ កម្មករនិយោជិតប្រភេទនេះមានជាអាទិ៍:-

-អ្នកទទួលខុសត្រូវថែទាំគ្រឿងម៉ាស៊ីន និងឋបនភ័ណ្ឌ

-អ្នកទទួលខុសត្រូវបោសសំអាត បំរើភ្ញៀវ បើកបរ និងជូតសជុលទីកន្លែងធ្វើការ

-អ្នកទទួលខុសត្រូវយាមកាមសហគ្រាស គ្រឹះស្ថាន។

ប្រការ២.- ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវមានតារាងបញ្ជីឈ្មោះ និងម៉ោងធ្វើការដោយឡែករបស់កម្មករនិយោជិតប្រភេទដូចមានចែងក្នុងប្រការ១ ខាងលើ ដែលត្រូវរក្សាទុកជាប្រចាំសំរាប់ការត្រួតពិនិត្យជាយ-ថាហេតុរបស់អធិការការងារ ។

ប្រការ៣.- កម្មករនិយោជិតប្រភេទដូចមានចែងក្នុងប្រការ១ ខាងលើមានសិទ្ធិ នឹងអនុវត្តដូចកម្មករនិយោជិតធម្មតា អំពីថិរវេលាធ្វើការ ការចែកពេលធ្វើការប្រចាំថ្ងៃ ប្រាក់ឈ្នួលពេលធ្វើការបន្ថែមម៉ោង និងការទូទាត់ម៉ោងធ្វើការដែលខកខានមិនបានធ្វើ ។

ប្រការ៤.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ៩២ សកអ.ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៥.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

  " ដើម្បីជូនជ្រាប "

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

  " ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "

- សមាគមនិយោជក
- សហព័ន្ធសហជីព

  " ដើម្បីជ្រាប "

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ " ដើម្បីជួយផ្សព្វផ្សាយ "
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ